**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ : ១៤៧/១៧ សសរ.៤

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការ និងក្រុមការងាររាជធានីភ្នំពេញ ដើម្បីចុះពិនិត្យដោះស្រាយ ផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ ដោយសារគម្រោងសាងសង់ ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដី និងអាកាស និងពង្រីកបណ្តាញចែកចាយ ក្នុងរាជធានីភ្នំពេញ (ជំហានទី១ និងទី២)

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- យោងលិខិតលេខ ១០០៩ លស.អក.ផយគ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ របស់អគ្គិសនីកម្ពុជា
- យោងតាមការចាំបាច់របស់រដ្ឋបាលរាជធានីភ្នំពេញ

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតអនុគណៈកម្មការរាជធានីភ្នំពេញ ដើម្បីពិនិត្យដោះស្រាយផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ ដោយសារគម្រោងសាងសង់ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដី និងអាកាស និងពង្រីកបណ្តាញចែកចាយក្នុងរាជធានីភ្នំពេញ ( ជំហានទី១ និងទី២ ) មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១ - ឯកឧត្តម **ឃួង ស្រេង** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | **ប្រធាន** |
| ២ - លោក ហួត ហៃ | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |
| ៣ - លោក វ៉ា សុធា | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤ - លោក ហុក ហូលីម | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៥ - តំណាងឯកឧត្តម ស្នងការនគរបាលរាជធានីភ្នំពេញ | | សមាជិក |
| ៦ - តំណាងឯកឧត្តម មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | | សមាជិក |
| ៧ - លោក សុខ សម្បត្តិ | អភិបាល នៃគណៈអភិបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ៨ - លោក ប៊ឹល កុសល | អភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ | សមាជិក |
| ៩ - លោក ហៃម ដារិទ្ធិ | អភិបាល នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ | សមាជិក |
| ១០-លោក សារិន វណ្ណា | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១១-លោក សៀង បូរិន | ប្រធានមន្ទីរកសិកម្ម | សមាជិក |
| ១២-លោក ងី ប៊ុនលី | ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ១៣-លោក គាត រង្សី | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១៤-លោក សាំ ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥- លោក កាំង លាងគ្រី | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស | សមាជិក |
| ១៦- លោក ស៊ិន បូណ៌មី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក |

**ប្រការ២.-**

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម ៖

- សហការជាមួយក្រុមការងារដោះស្រាយផលប៉ះពាល់អគ្គិសនីកម្ពុជា ដើម្បីចុះពិនិត្យដោះស្រាយផលប៉ះពាល់សំណង់ ដីធ្លី ផ្ទះសម្បែង និងដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋ ដោយសារគម្រោងសាងសង់ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដី និងអាកាស និងពង្រីកបណ្តាញចែកចាយក្នុងរាជធានីភ្នំពេញ (ជំហានទី១ និងទី២)។
- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមកើតមានឡើងដែលធ្វើឱ្យរាំងស្ទះដល់ការសាងសង់ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដី និងអាកាស និងពង្រីកបណ្តាញចែកចាយក្នុងរាជធានីភ្នំពេញ (ជំហានទី១ និងទី២)។
- រាយការណ៍ពីលទ្ធផលការងារ និងបញ្ហាប្រឈម ជូនឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ដើម្បីជ្រាប និងជាមូលដ្ឋានសំរាប់ពិនិត្យដោះស្រាយបន្ត។

អនុគណៈកម្មការនេះ នឹងបន្តការងារដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋក្នុងនាមជាគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់រាជធានីភ្នំពេញ ដើម្បីទទួលពិនិត្យពាក្យបណ្តឹង និងដោះស្រាយសមស្របនូវសំណូមពររបស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ដោយសារគម្រោងសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដី និងអាកាស និងពង្រីកបណ្តាញចែកចាយក្នុងរាជធានីភ្នំពេញ (ជំហានទី១ និងទី២)។

**ប្រការ៣**.-

ត្រូវបានបង្កើតក្រុមការងារជាជំនួយការអនុគណៈកម្មការរាជធានីភ្នំពេញ ដើម្បីចុះអនុវត្តការដោះស្រាយដោយផ្ទាល់ជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១ - | លោក ហុក ហួលីម | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | **ប្រធាន** |
| ២ - | លោក លន់ សោ | អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣ - | លោក កាំង លាងគ្រី | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស | សមាជិក |
| ៤ - | លោកស្រី អេង ច័ន្ទធរី | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ៥ - | លោក ហ៊ិន ប៊ុច | អនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| ៦ - | លោក ខាត់ សុខា | អនុប្រធានមន្ទីររ៉ែនិងថាមពល | សមាជិក |
| ៧ - | លោក ពៅ ម៉េងហៃ | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨ - | លោក ទី ដូរី | នាយករងទីចាត់ការរៀបចំក្រុង | សមាជិក |
| ៩ - | លោក ង៉ែត កែន | អនុប្រធានការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |
| ១០- | លោក ចាន់ គន្ថេត | នាយករដ្ឋបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ១១- | លោក មុត សុវណ្ណ | នាយករដ្ឋបាលខណ្ឌសែនសុខ | សមាជិក |
| ១២- | លោក យិន គា | នាយករដ្ឋបាលខណ្ឌពោធិ៍សែនជ័យ | សមាជិក |
| ១៣- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌព្រែកព្នៅ | | សមាជិក |
| ១៤- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌសែនសុខ | | សមាជិក |
| ១៥- | លោកតំណាងកងរាជអាវុធហត្ថមូលដ្ឋានខណ្ឌពោធិ៍សែនជ័យ | | សមាជិក |
| ១៦- | លោកតំណាងនគរបាលខណ្ឌព្រែកព្នៅ | | សមាជិក |
| ១៧- | លោកតំណាងនគរបាលខណ្ឌសែនសុខ | | សមាជិក |
| ១៨- | លោកតំណាងនគរបាលខណ្ឌពោធិ៍សែនជ័យ | | សមាជិក |
| ១៩- | លោកចៅសង្កាត់ពាក់ព័ន្ធ ក្នុងខណ្ឌនីមួយៗ | | សមាជិក |
| ២០- | លោកស្រី មាស រតនី | អនុប្រធានការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |
| ២១- | លោក ប៊ុន ម៉ានិត | មន្ត្រីការិយាល័យកិច្ចការច្បាប់និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |
| ២២- | លោក យៀម ជីវ័ន្ត | មន្ត្រីការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន | សមាជិក |

**ប្រការ៤.-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រុមការងារអគ្គិសនីកម្ពុជាចុះផ្សព្វផ្សាយ វាស់វែង ស្រង់ប្រមូលព័ត៌មានផលប៉ះពាល់ទាំងឡាយ ដែលពាក់ព័ន្ធនឹងគម្រោងសាងសង់ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់កប់ដីនិងអាកាស និងពង្រីកបណ្តាញចែកចាយក្នុងរាជធានីភ្នំពេញ (ជំហានទី១ និងទី២) និងសម្របសម្រួលដោះស្រាយការថ្នាំងថ្នាក់ចម្ងល់នានាជាមួយប្រជាពលរដ្ឋ។

- ធ្វើរបាយការណ៍ពីលទ្ធផលការងារនិងបញ្ហាប្រឈមជូនអនុគណៈកម្មការរាជធានីភ្នំពេញជាប្រចាំ។

**ប្រការ៥.-**

សមាជិកអនុគណៈកម្មការដោះស្រាយផលប៉ះពាល់រាជធានីភ្នំពេញ និងក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានសាមី។

សមាជិកគណៈកម្មការពិនិត្យដោះស្រាយបណ្តឹងតវ៉ារាជធានីដែលផ្ទេរភារកិច្ចពីអនុគណៈកម្មការដោះស្រាយផលប៉ះពាល់រាជធានីភ្នំពេញ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខណ្ឌព្រែកព្នៅ អភិបាលនៃគណៈអភិបាលខណ្ឌសែនសុខ អភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៧

**អភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

__កន្លែងទទួល :__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ក្រសួងរ៉ែ និងថាមពល
- អគ្គិសនីកម្ពុជា

« __ដើម្បីជូនជ្រាប__ »
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
- មន្ទីរកសិកម្ម
- មន្ទីររ៉ែ និងថាមពល
- មន្ទីរបរិស្ថាន
- រដ្ឋបាលខណ្ឌព្រែកព្នៅ សែនសុខ ពោធិ៍សែនជ័យ

« __ដើម្បីជ្រាប__ »
- សាមីខ្លួនដូចប្រការ៧

« __ដើម្បីអនុវត្ត__ »
- ឯកសារ-កាលប្បវត្តិ